ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សត្វាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៨៥
ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩
សាលដីកា
លេខ ៨៤ "II"
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន

២. លោក [redacted] ជាចៅក្រម

៣. លោក [redacted] ជាចៅក្រម

៤. លោក [redacted] ជាចៅក្រម

៥. លោកស្រី [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសាល និងឈ្មោះ [redacted] ធី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រV "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន ៖

-ជនជាប់ចោទ៖

១. ឈ្មោះ [redacted] ពិសាល ភេទប្រុស អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង និងមានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]



Scanned with CamScanner

[redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) និងប្រពន្ធឈ្មោះ [redacted] ជានីតិជន។ (កំពុងអនុវត្តទោសនៅពន្ធនាគារខេត្តព្រៃវែង)។ (អ្នកប្តឹងសាទុក្ខ)

២. ឈ្មោះ [redacted] ធី ហៅ [redacted] ធី ភេទប្រុស អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរតេម៉ូតូឌុប មានទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) និងប្រពន្ធឈ្មោះ [redacted] ជានីតិជន។ (សព្វថ្ងៃកំពុងឃុំខ្លួននៅពន្ធនាគារខេត្តកណ្តាល)។ (អ្នកប្តឹងសាទុក្ខ)

-មានលោកស្រី [redacted] សុរ៉ែន ជាមេធាវីការពារសិទ្ធិ។

-ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងចូលរួមក្រុមប្រដាប់អាវុធ ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧, មាត្រា ៤៨៤ និងមាត្រា ៤៨៥ នៃក្រមព្រហ្មទណ្ឌ។

## អំពីអង្គហេតុ

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ១៦និង២០នាទី ជនរងគ្រោះបានប្រមូលទ្រព្យសម្បត្តិមានមាស៩តំឡឹង លុយដុល្លា ៣ពាន់ដុល្លា លុយរៀល ១០លានរៀល និងលុយបាតមួយចំនួនទៀត ដាក់ក្នុងកាបូប រួចជិះម៉ូតូត្រឡប់មកផ្ទះ។ ពេលជិះមកដល់ចំណុចផ្លូវលំភូមិទួលអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ស្រាប់តែមានក្រុមចោរ ០២នាក់ជិះម៉ូតូរ៉ឺមៅ ពណ៌ក្រហម គ្មានស្លាកលេខ បើកគៀម៉ូតូឌុបជនរងគ្រោះឱ្យចូលខាង ហើយក្រុមចោរបានដកកាំភ្លើងខ្លី ភ្ជង់ជនរងគ្រោះ រួចឆក់យកកាបូបលុយ និងមាស រួចបើកម៉ូតូយ៉ាងលឿនដល់ភូមិក្បាលជ្រោយ ឃុំកំពង់ភ្នំ ក្រុមចោរបានទុកម៉ូតូចោលក្នុងព្រៃ ក្រោយវត្តកំពង់ភ្នំក្រៅ រួចនាំគ្នាឡើងជិះក្នុងរថយន្តម៉ាក Toyota Camry បាឡែន ពណ៌កណ្តុរប្រេះ ពាក់ស្លាកលេខ ២C ៩៦៩០ ដែលពួកវាចតចាំនៅទីនោះស្រាប់ រួចបើកឡានតាមផ្លូវជាតិលេខ១ ទៅភ្នំពេញ។ តាមការស្រាវជ្រាវរបស់សមត្ថកិច្ចគឺមានឈ្មោះ [redacted] ពិសាល ភេទប្រុស អាយុ ២៩ឆ្នាំ , ឈ្មោះ [redacted] ធី ភេទប្រុស អាយុ៣៣ឆ្នាំ និងគូកនពាក់ព័ន្ធក្នុងអង្គហេតុនេះ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តីលេខ ១២ "ញ" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅនេះ ៖

១-ឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ [redacted] ពិសាល ភេទប្រុស អាយុ ២៩ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា និងចូលរួមក្នុងក្រុមប្រដាប់អាវុធ ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៧ មាត្រា ៤៨៤ និងមាត្រា ៤៨៥ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧។

យោងតាមសាលក្រមមុនអង្គសេចក្តី ខាងលើនេះសាលាដំបូងខេត្តកណ្តាលបានសម្រេចបង្គាប់ឱ្យប្រធានពន្ធនាគារខេត្តព្រៃវែង ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ពិសាល ភេទប្រុស អាយុ ២៩ឆ្នាំ ដោយជនជាប់ចោទរូបនេះកំពុងត្រូវឃុំខ្លួននៅពន្ធនាគារនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ពីបទចែកចាយគ្រឿងញៀនផ្សេងមួយទៀត។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ញ) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ធី ពីបទ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា និងបទ ចូលរួមក្នុងក្រុមប្រដាប់អាវុធ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៧ មាត្រា ៤៨៤ និងមាត្រា ៤៨៥ នៃក្រមព្រហ្មទណ្ឌ មកជាបទ ទទួលផលចោរកម្មមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសជនជាប់ចោទៈ

២.១-ឈ្មោះ [redacted] ធី ភេទប្រុស អាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៦(ប្រាំមួយ)ឆ្នាំ។

ពីបទៈ ទទួលផលចោរកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ។

២.២- ឈ្មោះ [redacted] ពិសាល ភេទប្រុស អាយុ ២៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៧(ប្រាំពីរ)ឆ្នាំ។

ពីបទៈ លួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា និងបទ ចូលរួមក្នុងក្រុមប្រដាប់អាវុធ ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣, មាត្រា ៣៥៧ ,មាត្រា ៤៨៤ និងមាត្រា ៤៨៥ នៃក្រមព្រហ្មទណ្ឌ។

៣-រឹបអូសវត្ថុដែលចាប់យកមានៈ

៣.១-ម៉ូតូ ០១ គ្រឿង ម៉ាកវ៉េអេស ពណ៌ក្រហមលាយខ្មៅ មានលេខតួ RLHHC1209. BY306079 និងលេខម៉ាស៊ីន HC12 E-3106143 គ្មានស្លាកលេខ។

៣.២-រថយន្ត ០១ គ្រឿង ម៉ាកកាមរីបាឡែន ពណ៌កណ្តុរប្រមេះ ពាក់ស្លាកលេខ ភ្នំពេញ ២C-9690។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦, ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧, នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧



Scanned with CamScanner

ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធី និងចំពោះមុខជនជាប់ចោទឈ្មោះ ពេជ្រ ពិសាល ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ៅ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ ពេជ្រ ពិសាល ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៤ (ញ) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ០២១ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធី ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៤ (ញ) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រ V "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១. ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ០២០ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសាល និងបណ្តឹងឧទ្ធរណ៍លេខ ០២១ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ធី ទុកជាត្រឹមត្រូវតាមច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៤ (ញ) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការលើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ពិសាល ត្រូវកែប្រែពីការអនុវត្តទោសពន្ធនាគារ ៧(ប្រាំពីរ)ឆ្នាំ មកអនុវត្តទោសពន្ធនាគារ ៥(ប្រាំ)ឆ្នាំវិញ រីឯឈ្មោះ [redacted] ធី ពីការអនុវត្តទោសពន្ធនាគារ ៦(ប្រាំមួយ)ឆ្នាំ មកអនុវត្តទោសពន្ធនាគារ ៥(ប្រាំ)ឆ្នាំ វិញ។

ចំនុចផ្សេងៗពីនេះរក្សាទុកជាបានការដដែល។

៣. បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤. សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

សាលដីកានេះចូលជាស្ថាពរមានអនុភាពអនុវត្តតែលើឈ្មោះ [redacted] ពិសាល ។

សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួសហាការអនុវត្តសាលដីកានេះឱ្យសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

Scanned with CamScanner

-បានឃើញ ប្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសាល និងឈ្មោះ [redacted] ធី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រ V "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា សាលាឧទ្ធរណ៍បានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៤ (៣) ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ លើកលែងទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ពិសាល ត្រូវកែប្រែពីការអនុវត្តទោសពន្ធនាគារ ៧(ប្រាំពីរ)ឆ្នាំ មកអនុវត្តទោសពន្ធនាគារ ៥(ប្រាំ)ឆ្នាំ វិញ ឯឈ្មោះ [redacted] ធី ពីការអនុវត្តទោសពន្ធនាគារ ៦(ប្រាំមួយ)ឆ្នាំ មកអនុវត្តទោស ៥(ប្រាំ)ឆ្នាំ វិញ គឺជាការត្រឹមត្រូវហើយ។ ដោយផ្អែកតាមភស្តុតាងដាក់បន្ទុកបានបង្ហាញនៅក្នុង អង្គហេតុនោះគឺជនជាប់ចោទពិតជាបានប្រើប្រាស់មធ្យោបាយ រថយន្តបានឡែនដែលមានស្លាកលេខ ២C ៩៦៩០ដោយពុំមានលិខិតទិញ-លក់ ហើយតាមការស្រាវជ្រាវ ស្លាកលេខរថយន្តដែលបំពាក់លើរថយន្តម៉ាក ទីកូ មិនមែនបំពាក់លើរថយន្តបាឡែនពណ៌កណ្តុរប្រមេះទេ តបតាមរបាយការណ៍លេខ ១៥/២០១៥ រ.ប.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាល ស្រុកលើកដែក។ ដូចនេះជនជាប់ចោទពិតជាបានប្រើស្លាកលេខក្លែង ហើយបានចូលរួមប្រព្រឹត្តបទល្មើសដែលមានតួនាទីជាអ្នកបើករថយន្ត ការមើបាឡែនដែលពាក់ស្លាកលេខ ខាងលើចាំដឹកក្រុមរបស់ខ្លួនដែលបានធ្វើសកម្មភាពរួច។ ហើយម្យ៉ាងទៀតតាមការស្រាវជ្រាវរបស់អធិការរងបានសួរនាំទៅប្រជាជនឃើញថា រថយន្តនេះបានឈប់ចាំបក្សពួកនៅក្នុងវត្តតាសៀវ។ តាមការអះអាងជនជាប់ចោទបានទិញឡាននេះនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥ ក្រោយថ្ងៃកើតហេតុដែលផ្ទុយការអះអាងរបស់ប៉ូលីស បញ្ជាក់ រថយន្តនេះត្រូវបានឈ្មោះ [redacted] ធី ជិះជិតបាន ២ (ពីរ)ឆ្នាំហើយ ដូចនេះជនជាប់ចោទពិតជាបានឆ្លើយកុតកុហកទាំងស្រុង ហើយលាក់បាំង នៃអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត និងធ្វើសកម្មភាពប្លន់ ឬលួចទ្រព្យសម្បត្តិអ្នកដទៃបានសម្រេចពិតប្រាកដ។ ទោះបីជនជាប់ចោទទាំងពីរនាក់ បានឆ្លើយបដិសេធក៏ដោយ ក៏ពុំមានសញ្ញាណាមួយដែលអាចឱ្យតុលាការជឿជាក់បានដែរ។ បើផ្អែកតាមពាក្យស្នើសុំសាលដីកាព្រហ្មទណ្ឌស្តាពរចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ របស់ជនជាប់ចោទ ពេជ្រ ពិសាល បានយល់ព្រមទទួលស្គាល់ការអនុវត្តទោសពន្ធនាគាររួចស្រេចទៅហើយ ដូចនេះបណ្តឹងសាទុក្ខរបស់ជនជាប់ចោទពុំមានមូលដ្ឋានថ្មីមកពិចារណានោះឡើយ។ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។ សូមឯកឧត្តមប្រធានក្រុមប្រឹក្សាមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-លោកស្រីមេធាវី [redacted] សុវ៉ែន បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានសិក្សាសំណុំរឿង និងឆ្លងតាមសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ ខ្លួនយល់ថាដោយតែមានសាក្សីដោះបន្ទុកចំនួន ០៥រូប ដែល



Scanned with CamScanner

បានបញ្ជាក់យ៉ាងច្បាស់ថានៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោង ៤ ទៅម៉ោង ៥ គឺជនជាប់ចោទឈ្មោះ [redacted]ធី បាននៅចាំថែរក្សាមាន់ជល់របស់គាត់នៅផ្ទះដោយមិនចេញទៅណានោះទេ នេះជាចំណុចមួយ និងចំណុចមួយទៀតជនជាប់ចោទខ្លួនឯង គាត់ក៏បានឆ្លើយបំភ្លឺយ៉ាងច្បាស់ជូនតុលាការ តាំងពីនៅសមត្ថកិច្ច ហូតដល់សាលាដំបូង និងសាលាឧទ្ធរណ៍ ថាគាត់មិនបានចូលរួមក្នុងសកម្មភាពប្រព្រឹត្តអំពើលួច ដែលមានស្ថានទម្ងន់ទោសនោះទេ រួមជាមួយសាក្សីដែលបានឆ្លើយបំភ្លឺ តាំងពីដើមហូតមក គឺបញ្ជាក់យ៉ាងច្បាស់ថាគាត់នៅផ្ទះ គាត់មិនបានចូលរួមក្នុងសកម្មភាពនោះទេ ហើយគាត់ក៏មិនបានស្គាល់ឈ្មោះ [redacted]ពិសាល នោះដែរ។ ជនរងគ្រោះ និងកូនរបស់ជនរងគ្រោះ ក៏បញ្ជាក់ច្បាស់ដែលថាជនរងគ្រោះគឺគាត់ស្គាល់ជនជាប់ចោទច្បាស់ ហើយជនរងគ្រោះក៏ថាមិនបានចំណាំ ជនដែលបានប្លន់យកទ្រព្យសម្បត្តិរបស់គាត់ដែរ ហើយពេលនោះគាត់ក៏បានដកពាក្យបណ្ដឹងវិញផងដែរ។ អ៊ីចឹងចំណុចទាំងអស់នេះ ដែលខ្លួនបានលើកជូនអង្គជំនុំជម្រះនាពេលនេះ គឺជាកស្តុតាងដោះបន្ទុកមកលើជនជាប់ចោទឈ្មោះ [redacted] ធី។ ជាចុងក្រោយក្នុងនាមខ្លួនជាមេធាវីការពារជនជាប់ចោទ ស្នើសុំអង្គជំនុំជម្រះ ជាពិសេសតំណាងមហាអយ្យការ សុំមេត្តាពិចារណា បញ្ញត្តិមាត្រា ៣៨ ចំណុចទី៦ "វិមតិសង្ស័យ គឺត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

### សំអាងហេតុ

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់ឈ្មោះ [redacted] ពិសាល និងឈ្មោះ [redacted]ធី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted]ពិសាល និងឈ្មោះ [redacted] ធី បានប្ដឹងសាទុក្ខប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រV "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ភ្នំពេញ តាមសេចក្ដីសុំប្ដឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ក៏ប៉ុន្តែក្នុងអំឡុងពេលរដ្ឋបាលបញ្ជូនសំណុំរឿងនៅសាលាឧទ្ធរណ៍មកតុលាការកំពូលនោះ ជនជាប់ចោទឈ្មោះ [redacted]ពិសាល ក៏បានស្នើសុំសាលដីកាព្រហ្មទណ្ឌស្ថាពររបស់សាលាឧទ្ធរណ៍ តាមពាក្យសុំចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ ហើយសាលាឧទ្ធរណ៍ក៏បានបញ្ជាក់ស្ថាពរនៃសាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រV "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ដែលមានអនុភាពអនុវត្តចំពោះតែទណ្ឌិតឈ្មោះ [redacted] ពិសាល ចាប់ពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ រួចហើយដែរ ទើបសាលាឧទ្ធរណ៍បញ្ជូនសំណុំរឿង និងបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទទាំងពីរ មកកាន់តុលាការកំពូល។



Scanned with CamScanner

ករណីនេះចាត់ទុកថាជនជាប់ចោទឈ្មោះ [redacted] ពិសាល បោះបង់ចោលបណ្តឹងសាទុក្ខរបស់ខ្លួនវិញ ដែលតុលាការកំពូលគប្បីអនុវត្តតាមមាត្រា ៤៣៧ (ការបោះបង់ចោលបណ្តឹងសាទុក្ខ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជាវិបាក នាពេលសវនាការនេះ តុលាការកំពូលពិចារណាតែលើបណ្តឹងសាទុក្ខដែលធ្វើឡើងដោយជនជាប់ចោទឈ្មោះ [redacted] ធី ប៉ុណ្ណោះ។

៣-យល់ឃើញថា ការដែលមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] ធី ហៅ [redacted] ធី បានលើកឡើងនាពេលសវនាការជេញដោលនេះថា មានភស្តុតាងដោះបន្ទុកជាច្រើន ដូចជាសាក្សីជាដើម បង្ហាញថាកូនក្តីខ្លួនជាជនជាប់ចោទឈ្មោះ [redacted] ធី មិនបានចូលរួមប្រព្រឹត្តបទល្មើសជាមួយជនជាប់ចោទផ្សេងទៀតក្នុងការដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះនាថ្ងៃកើតហេតុថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ហេតុនេះស្នើឱ្យតុលាការសម្រេចឱ្យជនជាប់ចោទឈ្មោះ [redacted] ធី រួចខ្លួនពីបទចោទ ប្រកាន់តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ១៩៩៣ នោះជាការមិនត្រឹមត្រូវទេ ព្រោះថាជនជាប់ចោទឈ្មោះ [redacted] ធី ត្រូវបានតុលាការប្រកាសពិរុទ្ធភាព និងទោសក្នុងបទល្មើសទទួលផលចោរកម្មមានស្ថានទម្ងន់តាមមាត្រា ៣៩៩ និងមាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ ក្នុងអង្គហេតុនៃរឿងក្តីនេះមិនមែនប្រកាសទោសក្នុងបទល្មើសលួចដោយផ្ទាល់ ដែលមានសកម្មភាពដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិរបស់ជនរងគ្រោះទេ ហើយផ្ទុយទៅវិញភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ធី ក្នុងអំពើទទួលផលចោរកម្ម ត្រូវបានតុលាការអង្គហេតុធ្វើសំអាងហេតុច្បាស់លាស់អស់ហើយ ដែលតុលាការកំពូលសូមឯកភាពចំពោះសំអាងហេតុទាំងនេះ។

៤-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា រឿងក្តីនេះមានភស្តុតាងដាក់បន្ទុកជូនល្មមលើជនជាប់ចោទឈ្មោះ [redacted] ធី ហេតុនេះសុំតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ភ្នំពេញ។ ករណីនេះ តុលាការកំពូលបានពិចារណាដូចមានខាងលើនេះ។

៥-យល់ឃើញថា ភាគីជនជាប់ចោទត្រូវបានតុលាការជូនដំណឹងអំពីកាលបរិច្ឆេទនៃថ្ងៃសវនាការរួចរាល់ហើយ តែមិនបានចូលរួមនាពេលជេញដោលនេះទេ។ ដូច្នេះ តាមមាត្រា ៤៣៣ និង ៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អវត្តមានភាគីក្តីមិនមែនជាឧបសគ្គនៃនីតិវិធីជេញដោលនាពេលនេះទេ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រV "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកលើជនជាប់ចោទឈ្មោះ [redacted] ធី នេះត្រឹមត្រូវហើយ។

## ហេតុដូច្នេះ

## សម្រេច

១-ទទួលស្គាល់ការបោះបង់ចោទបណ្តឹងសាទុក្ខ និងបដិសេធបណ្តឹងសាទុក្ខលេខ ៣៥២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសាល និងឈ្មោះ [redacted] ធី។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦០ ក្រV "ច" ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីលើជនជាប់ចោទឈ្មោះ អ៊ុក ធី ទុកជាបានការ។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner